ការពិនិត្យមើលតាមរយៈសម្លេង

The Royal Women's Hospital Fact Sheet / www.thewomens.org.au

the women's
the royal women's hospital
victoria australia

តើ ULTRASOUND ជាអ្វីទៅ?

ការពិនិត្យ ultrasound ប្រើរលកសម្លេងមានប្រេកង់ខ្ពស់ ដើម្បីពិនិត្យខាងក្នុងរាងកាយ។ រលកសម្លេង មានកំរិតកំពស់ខ្ពស់ជាខ្លាំងដែលត្រចៀកមនុស្សយើងមិនអាចស្តាប់ឮបាន។ រលកសម្លេងត្រូវបានតម្រង់ទៅកាន់ផ្នែកខាងក្នុងនៃរាងកាយ តាមរយៈគ្រឿងស្តាប់ញ័រតូចមួយ នៅក្នុងឧបករណ៍ពិនិត្យពិច័យកាន់នៅនឹងដៃ (ហៅថា tranducer)។ ឧបករណ៍ពិនិត្យពិច័យនេះ ឆ្លុះបញ្ចាំងមកវិញនូវសម្លេងឬ"សម្លេងខ្ទ័រជះមកវិញ" ដើម្បីបង្កើតរូបភាពមួយ។

ការពិនិត្យ ultrasound មិនអាចបង្កើតរូបភាពមានគុណភាពខ្ពស់ទេ ប៉ុន្តែវាមិនចាំបាច់ចូលទៅក្នុងរាងកាយអ្នក ហើយមិនប្រើវិទ្យុសកម្មឡើយ។ វិធីនេះត្រូវបានប្រើជាទូទៅដើម្បីសិក្សាសរីរាង្គនៅក្នុងពោះ សរីរាង្គក្នុងរង្វង់ឆ្អឹងត្រគាក និង ជាលិកាដោះ។

ការពិនិត្យ ultrasound មានប្រយោជន៍ជាពិសេសសំរាប់ការស្វែងរកភាពមិនប្រក្រតីនៃផ្ទៃពោះ និងនៅក្នុងសរីរាង្គក្នុងរង្វង់ឆ្អឹងត្រគាករបស់ស្ត្រី។

តើគេធ្វើតេស្តនេះតាមរបៀបណា?

មុនពេលធ្វើការពិនិត្យពិច័យនេះ គេលាបប្រេងអង្គិលទៅលើស្បែកដើម្បីអនុញ្ញាតឲ្យរលក ultrasound ចេញពីឧបករណ៍ transducer ចូលទៅក្នុងរាងកាយ។ គេរុញឧបករណ៍ transducer ចុះឡើងពីលើស្បែកនោះរហូតទាល់តែគេអាចមើលឃើញរូបភាពមួយ។ ជាទីបញ្ចប់ គេដាក់ឧបករណ៍ transducer នេះឲ្យនៅនឹងមួយកន្លែង នៅក្នុងពេលកត់ត្រារូបភាព។

តើប្តេកនោមត្រូវតែមានទឹកនោមពេញឬទេ?

នៅពេលដែលស្ត្រីគ្មានផ្ទៃពោះ ឬនៅនឹងពេលប៉ុន្មានអាទិត្យដំបូងនៃការមានផ្ទៃពោះ ស្បូនគឺជាអូវែរស្ថិតនៅនឹងទីជំរៅនៅក្នុងរង្វង់ឆ្អឹងត្រគាក ហើយជាញឹកញយ ត្រូវបានហ៊ុមព័ទ្ធទៅដោយពោះវៀន។ ultrasound មិនអាចឆ្លងកាត់ពោះវៀនមានឧស្ម័នបានឡើយ។ ដូច្នេះ គេប្រហែលជាគ្មានលទ្ធភាពដើម្បីមើលចូលទៅក្នុងរង្វង់ឆ្អឹងត្រគាក និង ស្បូនឡើយ។ ប្តេកនោមដែលមានទឹកនោមខ្ទះនៅក្នុងនោះ ជួយរុញច្រានពោះវៀនចេញពីទីនោះ។

នៅពេលក្រោយមកទៀតនៃការមានផ្ទៃពោះ នៅពេលដែលស្បូនឈ៖ចេញពីរង្វង់ឆ្អឹងត្រគាករួច ហើយនោះ ប្តេកនោមដែលមានទឹកនោមខ្ទះ ធ្វើឲ្យរឹតតែងាយស្រួលក្នុងការមើលឃើញផ្នែកខាងក្រោមរបស់ស្បូន។ អំពើនេះជួយធ្វើឲ្យប្រាកដថា សុក(ក្រោយពីសំរាលកូនហើយ) មិនស្ថិតនៅផ្នែកខាងក្រោមទេ ហើយមិនកំពុងស្ថិតនៅពីខាងមុខទារកឡើយ។ ដោយមានសំភារៈទំនើប ប្តេកនោម ពេញ*ខ្លាំង* មិនមែនជាការចាំបាច់ទេ។

តើការពិនិត្យ ULTRASOUND បង្កឲ្យមានការខូចខាតឬទេ?

តេស្ត ultrasound បានត្រូវប្រើចំពោះស្ត្រីមានផ្ទៃពោះ អស់ពេលជិត 30 ឆ្នាំមកហើយ។ ទោះជាមានការសិក្សាអង្កេតយ៉ាងខ្លាំងក្លាដោយក្រុមស្រាវជ្រាវជាច្រើនក្តី ក៏គេមិនបានរកឃើញភស្តុតាងដើម្បីផ្តល់មតិថា ការពិនិត្យនេះបង្កគ្រោះថ្នាក់ណាមួយដល់ទារកដែលកំពុងធំលូតលាស់ ឬ ដល់ម្តាយឡើយ។ នៅក្នុងប្រទេសខ្លះ ការពិនិត្យ ultrasound យ៉ាងហោចណាស់ក៏ម្តងដែរចំពោះផ្ទៃពោះទាំងអស់ គឺជាកិច្ចការជាប្រចាំ ហើយត្រូវបានប្រើជាទូទៅនៅក្នុងបណ្តាប្រទេសរីកចំរើន។

តើការពិនិត្យ ULTRASOUND មានកំរិតកំណត់ឬទេ?

នៅក្នុងពេលដែលការពិនិត្យ ultrasound អាចផ្តល់ពត៌មានដ៏មានតម្លៃខ្លាំងអំពីផ្ទៃពោះ ហើយអាចតាមរកមើលភាពមិនប្រក្រតីណាមួយរបស់ទារកក្នុងផ្ទៃក្តី ក៏ការពិនិត្យនេះមិនអាចផ្តល់ចម្លើយច្បាស់លាស់ទៅនឹងបញ្ហាគ្រប់យ៉ាង នៅគ្រប់ឱកាសឡើយ។ ការពិនិត្យ ultrasound មិនអាចធានាប្រាប់ថា ទារកនឹងមានលក្ខណៈប្រក្រតីយ៉ាងលំអិតឡើយ។

នៅក្នុងស្ថានការណ៍ឯទៀត ដូចជាការពិនិត្យមើលស្ត្រីដែលមានការឈឺចាប់ឬមានជុំសាច់ គេត្រូវមើលរូបភាពតាម ultrasound ព្រមជាមួយនឹងលទ្ធផលនៃប្រភេទតេស្តផ្សេងទៀតជានិច្ច។

ហេតុអ្វីបានជាប្រើ ULTRASOUND នៅពេលមានផ្ទៃពោះ?

មូលហេតុទូទៅបំផុតចំពោះការពិនិត្យ ultrasound ក្នុងអម្លុងពេលមានផ្ទៃពោះ គឺ :

- ឲ្យដឹងពេលដែលត្រូវសំរាលកូន
- ឲ្យដឹងថា តើមានការចេញឈាមនៅពេលមានផ្ទៃពោះនៅគ្រាដំបូងឬទេ ហើយថាតើផ្ទៃពោះនោះកំពុងតែមានដំណើរការទៅដោយធម្មតាឬទេ
- ឲ្យដឹងថា តើមានទារកច្រើនជាងមួយនៅក្នុងផ្ទៃឬទេ
- ឲ្យដឹងថា តើមានការចេញឈាមនៅអម្លុងពេលក្រោយមកទៀតនៃការមានផ្ទៃពោះឬទេ ដោយសារតែការពិនិត្យនេះនឹងបង្ហាញទីតាំងរបស់សុក
- ឆែកមើលការលូតលាស់ផ្នែករាងកាយរបស់ទារក ហើយធានាទៅតាមលទ្ធភាពថា ទារកនេះគ្មានបញ្ហាណាដែលជាភាពមិនប្រក្រតីឡើយ
- ឲ្យដឹងថា នៅពេលក្រោយមកទៀតនៃការមានផ្ទៃពោះ ទារកបានធំលូតលាស់ទៅតាមទំហំដែលយើងសង្ឃឹមទុក សំរាប់ដំណាក់កាលនៃផ្ទៃពោះនោះ។

ការពិនិត្យ ultrasound ណាមួយដែលធ្វើទៅក្នុងអម្លុងពេលមានផ្ទៃពោះ នឹងឆែករកមើលស្ថានភាពភាគច្រើនបំផុត ដែលបានលើកឡើងនៅក្នុងបញ្ជីខាងលើនេះ។

ក្រោយពីខែទីបី (ចាប់ពី 15-16 អាទិត្យ និងក្រោយពីនេះ) គេអាចឃើញយ៉ាងលំអិតនូវដៃជើង និងសរីរាង្គជាច្រើនរបស់ទារក ដោយមានរួមទាំងឆ្អឹងខ្នង ពោះ ល្ហុកនោម និង បេះដូង។

ជាអកុសល គេគ្មានលទ្ធភាពធ្វើរោគវិនិច្ឆ័យជម្ងឺលីលើម្យ៉ាងហៅថា Down's Syndrome (mongolism) ក្នុងអម្ចងការពិនិត្យនេះទេ។ យ៉ាងណាមិញ ការពិនិត្យនេះអាចរកមើលដឹងបញ្ហានៃភាពមិនប្រក្រតីជាច្រើនផ្សេងទៀត។

តើ ULTRASOUND អាចមានប្រយោជន៍អ្វីខ្លះទៀត?

ដោយសារតែ ultrasound ផ្តល់រូបភាពជាបន្តបន្ទាប់ ដូច្នេះការពិនិត្យនេះជាការមានប្រយោជន៍ណាស់សំរាប់តំណែតំរង់ម្ជុលចាក់ចូលទៅក្នុងទីជំហរមួយ ក្នុងរង្វង់រាងកាយ។ ទម្រង់ការមួយដូចជាតេស្តបូមទឹកភ្លោះក្នុងស្បូនដើម្បីពិនិត្យសុខភាពទារកក្នុងផ្ទៃមាតា (បូមយកទឹកភ្លោះខ្លះចេញពីកន្ទែងជុំវិញទារក) ត្រូវបានធ្វើឡើង នៅក្នុងពេលប្រើ ultrasound ដើម្បីមើលម្ជុលដែលចាក់ទៅក្នុងផ្ទៃពោះ។

ចំពោះអ្នកជម្ងឺខ្លះដែលគ្មានផ្ទៃពោះ អង្គធាតុរាវអាចត្រូវបានបូមយកចេញពីថង់នៅលើអូវែរ ហើយនៅក្នុងការព្យាបាលជួយបង្កើតកូននៅក្រៅផ្ទៃពោះម្តាយ (Invitro Fertilization treatment - IVF) ពងជីវិតរបស់ស្ត្រីអាចត្រូវបានដកយកចេញពីអូវែរ តាមវិធីស្រដៀងគ្នានេះ។

តើរូបថតទាំងឡាយ មានរូបភាពដូចម្តេចទៅ?

ការពិនិត្យ ultrasound ផ្តល់រូបភាពតែមួយបន្ទះឬមួយផ្នែកតែប៉ុណ្ណោះ នៅគ្រាម្តងៗ។ រូបភាពនេះគឺប្រៀបដូចជាមើលទៅកាន់ធ្លុងបន្ទះមួយចំណិតយ៉ាងដូច្នោះដែរ។ រូបភាពទាំងឡាយដែលមើលឃើញនៅលើអេក្រង់ មិនបង្ហាញរូបទារកទាំងមូលនៅគ្រាមួយលើកទេ ប៉ុន្តែជារូបភាពមួយបន្ទះតែប៉ុណ្ណោះ។ រូបភាពមួយ ដែលបង្ហាញក្បាលនិងរាងកាយនៃទារក មិនទំនងជារួមបញ្ចូលទាំងដៃនិងជើងរបស់ទារកឡើយ។ ក្នុងអម្ចងការពិនិត្យនេះ កិច្ចខិតខំគ្រប់យ៉ាងនឹងត្រូវបានធ្វើឡើង ដើម្បីបង្ហាញលោកអ្នកគ្រូពេទ្យដែលចង់មើលឃើញ នៅលើអេក្រង់។

រួចចុះអំពីការពិនិត្យពិច័យមើលយោនីវិញគោះ?

គេមានលទ្ធភាពពិនិត្យពិច័យអ្នកជម្ងឺតាមរយៈយោនី ដោយប្រើឧបករណ៍ដែលរៀបចំជាពិសេស។ អ្នកជម្ងឺត្រូវបង្ហូរបង់ទឹកនោមចេញជាមុន ហើយឧបករណ៍ពិនិត្យតូចមួយត្រូវបានដាក់ចូលទៅក្នុងយោនី។

អ្នកជម្ងឺអាចមានភាពមិនសុខស្រួលតិចតួច ប៉ុន្តែទម្រង់ការនេះនឹងមិនបង្កគ្រោះថ្នាក់ដល់ទារកក្នុងផ្ទៃឡើយ។ ចំពោះអ្នកជម្ងឺដែលគ្មានផ្ទៃពោះវិញ ឬ នៅក្នុងដំណាក់កាលដំបូងនៃការមានផ្ទៃពោះ ជាញឹកញយ វិធីនេះផ្តល់រូបភាពកាន់តែប្រសើរឡើង ហេតុដូច្នេះវាផ្តល់ពត៌មានច្រើនថែមទៀត។

Disclaimer The Royal Women's Hospital does not accept any liability to any person for the information or advice (or use of such information or advice) which is provided in this fact sheet or incorporated into it by reference. We provide this information on the understanding that all persons accessing it take responsibility for assessing its relevance and accuracy. Women are encouraged to discuss their health needs with a health practitioner. If you have concerns about your health, you should seek advice from your health care provider or if you require urgent care you should go to the nearest hospital Emergency Department. © The Royal Women's Hospital, March 2014